00824864

E200/4

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
19 / 07 / 2012
ម៉ោង (Time/Heure): 14 : 20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**សាធារណៈ / Public**

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

**ជូនចំពោះ:** **ភាគីនៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម; មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង; អង្គភាពគាំពារសាក្សី និងអ្នកជំនាញ**

**កម្មវត្ថុ:** **ការអនុញ្ញាតឱ្យប្រើប្រាស់ទម្រង់នៃលិខិតធានាអះអាងអំពីការមិនចោទប្រកាន**

១. កាលពីថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់អំពីជំហរដំបូងរបស់ខ្លួនស្តីអំពីសំណើរបស់សហព្រះរាជអាជ្ញាសុំការអនុញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា (ឯកសារ E200) ("សំណើ") និងបានចែកចាយសំណៅព្រាងមួយច្បាប់ដែលអង្គជំនុំជម្រះបានកែប្រែលើទម្រង់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដែលសហព្រះរាជអាជ្ញាបានស្នើឡើង (ឯកសារ E200/3 និងឯកសារ E200/3.1 ដាច់ដោយឡែកពីគ្នា)។ អង្គជំនុំជម្រះបានស្នើក្រុមមេធាវីការពារក្តីឱ្យបង្ហាញការជំទាស់របស់ពួកគេទៅនឹងឯកសារ E200/3.1 (ប្រសិនបើមាន) ឱ្យបានត្រឹមថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២។ សំណើចំនួន ០២ ស្នើសុំការពន្យារពេលដែលមេធាវីការពារជនជាប់ចោទ ខៀវ សំផន និងជនជាប់ចោទ អៀង សារី បានដាក់ (ឯកសារ E200/1 និងឯកសារ

E200/2 ដាច់ដោយឡែកពីគ្នា) ពុំត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឡើយ ដោយហេតុថាអង្គជំនុំជម្រះយល់ឃើញថាបញ្ហានេះ ស្ថិតនៅក្រោមឆន្ទានុសិទ្ធិរួមរបស់ខ្លួនក្នុងការរៀបចំកិច្ចដំណើរនីតិវិធី និងពុំតម្រូវឱ្យមានការពិភាក្សាតទល់អូសបន្លាយឡើយ។ បើទោះជាបែបនេះក្តី មេធាវីការពារជនជាប់ចោទ អៀង សារី បានដាក់ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាកាលពីថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១២ (ឯកសារ E200/1/1) ដែលអង្គជំនុំជម្រះបានទទួលយក ("ចម្លើយតប")។

២. គោលបំណងសំខាន់នៃសំណើខាងលើគឺថាលិខិតធានាអះអាងអំពីការមិនចោទប្រកាន់ ដូចដែលសហព្រះរាជអាជ្ញាបានស្នើ មានលក្ខណៈទូលំទូលាយពេក និងអាចបង្កើតការភាន់ច្រឡំ ដោយហេតុថាលិខិតនេះធ្វើឱ្យមានការសន្និដ្ឋានថាសាក្សីនឹងពុំត្រូវបានចោទប្រកាន់ក្នុងតុលាការផ្សេងក្រៅពី អ.វ.ត.ក ឡើយ។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានគូសបញ្ជាក់ថាខ្លួន "យល់ឃើញថាជាការពុំសមស្រប ដោយយោងទៅលើតួនាទី និងក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក ក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់នៅចំពោះមុខតុលាការកម្ពុជា" (ឯកសារ E200/3)។ បន្ទាប់ពីពិនិត្យមើលឡើងវិញទៅលើចម្លើយតបខាងលើ អង្គជំនុំជម្រះយល់ឃើញថាការជំទាស់ជាចម្បងរបស់មេធាវីការពារជនជាប់ចោទ អៀង សារី គឺបានផ្តោតជាសំខាន់លើសេចក្តីព្រាងដែលបានកែសម្រួល E200/3.1 របស់អង្គជំនុំជម្រះ។

៣. មេធាវីការពារជនជាប់ចោទ អៀង សារី បានលើកចំណុចចំនួន ០២ ថែមទៀតនៅក្នុងចម្លើយតបរបស់ខ្លួន។ ចំណុចទីមួយ មេធាវីការពារជនជាប់ចោទ អៀង សារី បានលើកឡើងថាការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីពុំមានភាពចាំបាច់ឡើយ ដោយយោងទៅលើយន្តការដែលមានស្រាប់នាពេលបច្ចុប្បន្នដូចជា ការធ្វើសម្បថរបស់សាក្សីមុនពេលផ្តល់សក្ខីកម្ម និងនីតិវិធីដែលមានចែងក្នុងវិធាន ២៨ និងវិធាន ៣៦ នៃវិធានផ្ទៃក្នុង។ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ អង្គជំនុំជម្រះយល់ឃើញថាការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់នឹងបំពេញបន្ថែមលើនីតិវិធីដែលមានស្រាប់ និងជួយដល់ភារកិច្ចរបស់អង្គជំនុំជម្រះក្នុងការបញ្ជាក់ការពិត។ ចំណុចទីពីរ មេធាវីការពារជនជាប់ចោទ អៀង សារី អះអាងថាជាការពុំត្រឹមត្រូវឡើយដែលសហព្រះរាជអាជ្ញាប្រាស្រ័យទាក់ទងជាមួយសាក្សី។ អង្គជំនុំជម្រះសូមរំឭកថានាពេលកន្លងមកអង្គជំនុំជម្រះធ្លាប់បានអនុញ្ញាតឱ្យភាគីជួបទាក់ទងជាមួយសាក្សីសម្រាប់គោលបំណងតូចតាចដែលមានកំហិតច្បាស់លាស់ប៉ុណ្ណោះ (*ឧទាហរណ៍ សូមមើល* អនុស្សរណៈរបស់អង្គជំនុំជម្រះ

សាលាដំបូងដែលមានចំណងជើងថា ការស្តាប់សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-38 និង TCE-44 (ឯកសារ E166))។ ប៉ុន្តែក្នុងករណីបែបណាក៏ដោយ លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៅ អ.វ.ត.ក ត្រូវផ្តល់ទៅសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងទម្រង់ជាលាយលក្ខណ៍អក្សរតាមរយៈអង្គភាពគាំពារ សាក្សី និងអ្នកជំនាញ។

៤. អង្គភាពគាំពារសាក្សី និងអ្នកជំនាញអាចចាប់ផ្តើមប្រគល់ឲ្យសាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណីនូវលិខិតធានាអះអាងអំពីការមិនចោទប្រកាន់នៅក្នុងទម្រង់ឧបសម្ព័ន្ធ១ ដែលភ្ជាប់មកជាមួយនឹងអនុស្សរណៈនេះ ដោយអនុលោមតាមនីតិវិធីដូចមានចែងខាងលើ។